ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០១៦/១៣ ក.ស.ជ អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមករា ឆ្នាំ២០១៣

## និងទិសដៅការងារ ខែកុម្ភៈ ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/០១/២០១៣ ដល់ ថ្ងៃទី ៣១/០១/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តន៍តាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្តន៍ "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុងខែមករា ឆ្នាំ២០១៣ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែមករា ឆ្នាំ២០១៣ នេះ តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ បានបង្ហាញថា សកម្មភាពចរាចរ ជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមានគួរឱ្យកត់សំគាល់ ។ ជាក់ស្តែងនៅក្នុងខែមករានេះ អង្គភាពដែលបានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន និង រាជធានី-ខេត្តចំនួន ១២ គឺ រាជធានីភ្នំពេញ ខេត្តព្រះសីហនុ កណ្តាល តាកែវ កំពង់ចាម សៀមរាប ស្ទឹងត្រែង រតនគិរី បាត់ដំបង បន្ទាយមានជ័យ ក្រចេះ និង ឧត្តរមានជ័យ ដែលបានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនជាក់ស្តែង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ប្រៀបធៀបខែធ្នូ ឆ្នាំ២០១២ កន្លងទៅ ចំនួនបទល្មើសដែលបង្ក្រាបបាន មានការថយចុះ ១៨ ករណី ។ គ្រឿងញៀនទាំងនោះ ភាគច្រើននៅតែបន្តនាំមកពីតំបន់ត្រីកោណមាស ហើយហូរចូលមកកម្ពុជា តាមច្រកនៃបណ្តាខេត្តនៅភាគឦសាន ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *១. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ , Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

- បានបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងឱកាសជួបសំណេះសំណាលជាមួយក្រុមយុវជនគណបក្សប្រជាជនកម្ពុជា ខេត្តបន្ទាយមានជ័យ ប្រមាណជាង ៥០០ នាក់ ( ថ្ងៃទី១៧ មករា ២០១៣) ។
- បានអនុញ្ញាតឱ្យមន្ត្រីនៃមណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋ ទៅទទួលវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាស្វែងយល់ពីការងារគ្រប់គ្រងមណ្ឌលព្យាបាល ។
- បានឯកភាពជាគោលការណ៍ ឱ្យចាត់តាំងមន្ត្រីបង្គោលសម្រាប់ផ្តល់និងទទួលព័ត៌មានតាមប្រព័ន្ធអ៊ីនធ័រណែត ពីក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ (INCB) ពាក់ព័ន្ធនឹងព័ត៌មានស្តីពីឧបទ្ទវហេតុនានា នៃសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងសារធាតុគីមី ។
- បានណែនាំឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បន្តសហការជាមួយក្រសួងសុខាភិបាល ជំរុញសេវាព្យាបាលដោយផ្អែកលើសហគមន៍តាមបណ្តារាជធានី-ខេត្ត ដោយយកគំរូតាមខេត្តបន្ទាយមានជ័យ ។
- បានណែនាំឱ្យរៀបចំគណៈប្រតិភូអន្តរក្រសួងទៅធ្វើទស្សនកិច្ចនៅខេត្តយូណាន ប្រទេសចិន ដោយមានបញ្ចូលសមាសភាពខេត្តបន្ទាយមានជ័យ ។
- បានណែនាំឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយក្រសួងពាក់ព័ន្ធដើម្បី :
  - ✓ រៀបចំផែនការសកម្មភាពជាក់លាក់ ជំរុញការអនុវត្តខ្លឹមសារនៃកំណត់ហេតុកិច្ចប្រជុំទ្វេភាគី កម្ពុជា-វៀតណាម ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ ពិសេសរៀបចំផែនការសកម្មភាពសម្រាប់ជំរុញភាគីវៀតណាម ក្នុងដំណើរការជួយកសាងមជ្ឈមណ្ឌលជាតិ សម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅកម្ពុជា ។
  - ✓ បន្ថែមក្របខណ្ឌមន្ត្រីចំនួន ២៥ កន្លែង ជូនដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់បម្រើការងារនៅក្នុងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងបញ្ជូនទៅបណ្តុះបណ្តាលនៅប្រទេសវៀតណាម ឆ្នាំ២០១៣ ។
  - ✓ ទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំទ្វេភាគី ត្រីភាគី ថ្នាក់រដ្ឋមន្ត្រី កម្ពុជា វៀតណាម ឡាវ លើកទី១៣ នៅខេត្តសៀមរាប ។
- បានណែនាំឱ្យរៀបចំពិធីប្រគល់សម្ភារជូលដល់បណ្ឌិត្យសភានគរបាលកម្ពុជា សម្រាប់កម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ដល់សាលាមធ្យមវិជ្ជាជីវៈនៃគរបាល, សាលាមធ្យមបច្ចេកទេសនគរបាល, សាលានគរបាលជាតិ ភូមិភាគ១ ខេត្តស្ទឹងត្រែង, សាលានគរបាលជាតិ ភូមិភាគ២ ខេត្តកំពង់ចាម, សាលានគរបាលជាតិភូមិភាគ៦ ខេត្តកំពង់ឆ្នាំង ។
- បានអនុញ្ញាតឱ្យមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន មន្ត្រីតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ត្រីតំណាងក្រសួងសុខាភិបាលនិងគ្រូពេទ្យនៃមណ្ឌលបណ្តោះអាសន្នឱកាសខ្ញុំ ពិភពនៃក្តីសង្ឃឹម មណ្ឌល

កងរាជអាវុធហត្ថខេត្តបាត់ដំបង-បន្ទាយមានជ័យ និងជីវិតថ្មីភ្នំបាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសថៃ ។

- បានអនុញ្ញាតឱ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំពិធីទទួលសម្ភារ ពីគម្រោង PATROL របស់អង្គការ UNODC សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន និងទទួលសម្ភារ ពីគម្រោងនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៃបណ្តាប្រទេសតាមដងទន្លេមេគង្គ របស់អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ។
- បានអនុម័តនិងចុះហត្ថលេខា លើសេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាព តួនាទី និងភារកិច្ចការិយាល័យទំនាក់ទំនងព្រំដែន (Border Liaison Office.(BLO) ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាអនុវត្តតាមទិសដៅការងារដែលបានដាក់ចេញកាលពីខែវិច្ឆិកាកន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តយុទ្ធសាស្ត្រពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

## ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័នជាសមាជិក បានបន្តយកចិត្តទុកដាក់អនុវត្តន៍ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ ដែលក្នុងនោះរួមមាន ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី ក្រសួងធម្មការនិងសាសនា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងទេសចរណ៍ ។

**ដោយឡែក** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ តាមកម្មវិធីប្រចាំខែ ដែលផ្តល់ដោយស្ថានីយ៍ទូរទស្សន៍ ស៊ី.ធី.អិន (C.T.N) និង ស៊ី.អិន.ស៊ី (C.N.C) បានផ្តល់នូវកិច្ចសម្ភាសន៍ក្នុងកម្មវិធី សភាអ៊ីនធឺណែតស្តីពី "យុទ្ធសាស្ត្រជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿង" កាលពីថ្ងៃទី ៣០/០១/២០១៣ ។ ជាមួយនេះ ក៏បានបន្តការគាំទ្រដល់អង្គការពន្លឺកុមារកម្ពុជា ក្នុងការបន្តអនុវត្តសកម្មភាព និងកម្មវិធី IOGT-NTO Movement នៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

**ជាមួយនេះដែរ** ការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនទៅតាមសហគមន៍ ក៏ត្រូវបានក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គីសនីកម្ពុជា និងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមអនុវត្តន៍យ៉ាងផុលផុសតាមគ្រប់រូបភាព **ដែលសកម្មភាពទាំងអស់នោះមាននៅក្នុងឧបសម្ព័ន្ធទី១** ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាគ្រឿងញៀន ដែលបានអនុវត្តដោយក្រសួង-ស្ថាប័នរដ្ឋជាសមាជិក , ក្រសួង ស្ថាប័នរដ្ឋដែលមិនមែនជាសមាជិក អ.ជ.ប.គ.ញ ( អគ្គីសនីកម្ពុជា និង ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច), អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ៤ គឺ ខេត្តព្រះវិហារ ខេត្តតាកែវ ខេត្តក្រចេះ និង ខេត្តកំពង់ស្ពឺ នៅក្នុងខែមករា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួមសរុប ***៤០.៧២០*** នាក់ លើ ៤៦.៤០១ នាក់ នៃខែធ្នូ ឆ្នាំ២០១២ ។

## ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

ក្នុងខែមករា ឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់សមាសភាពនិងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### ខ.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៦២** ករណី
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **១៥០** នាក់
- **ចាប់តាមដីកា មាន** ៣ ដីកា = ៣ នាក់ ( ប្រុស) ជនជាតិខ្មែរ

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **១៥០** នាក់ ខាងលើ មានប្រុស ១២១ នាក់ ស្រី ២៩ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ១៣៧ នាក់ ( ស្រី ២៤ នាក់) , **វៀតណាម** ១១ នាក់ ( ស្រី ៥ នាក់) , ជនជាតិឡាវ ២ នាក់ ( ប្រុស) ។ ត្រូវបានសមត្ថកិច្ច កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីន (WY) ៨៧៣ គ្រាប់ និង ១.៨៣៨,៦ ក្រាម មេតំហ្វេតាមីនក្រាមម្សៅ (Ice) ១.២៨៨,៤១ ក្រាម , ហេរ៉ូអ៊ីន ៦.០៣៥,៦ ក្រាម , កញ្ឆាក្រៀម ៩,១ ក្រាម , ម្សៅពណ៌ស ជាសារធាតុផ្សំ ៥ បាវ ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក** រួមមាន :
  រថយន្ត ៤ គ្រឿង , ម៉ូតូ ២៤ គ្រឿង , ប្រាក់កម្ពុជា ១.៧៨១.៣០០ រៀល , ប្រាក់អាមេរិក ៧.៨៨១ ដុល្លារ , ប្រាក់វៀតណាម ១១.០០០ ដុង , ប្រាក់ឡាវ ៥០០ គីប ។
- **អចលនទ្រព្យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** រក្សាទុកសម្រាប់ជម្រះក្តី រួមមាន ៥ គោលដៅគឺ :
  - គោលដៅទី១ : ផ្ទះលេខ ២៦AB ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ( កន្លែងចាប់បានហេរ៉ូអ៊ីន ១៧ ដុំ = ៦ គ.ក្រ ០៣៥ ក្រាម ៦) ។
  - គោលដៅទី២ : ផ្ទះលេខ ៩២ ស្ទួន ផ្លូវបេតុង ក្រុម ៨ ភូមិបាសាក់ ១ ស.ក ព្រែកប្រា ខណ្ឌមានជ័យ ។
  - គោលដៅទី៣ : ផ្ទះលេខ ៣៦AE ផ្លូវលេខ ២០២ ស.ក ទឹកថ្លា ខណ្ឌទួលគោក ( កន្លែងដែលមានពុម្ពផលិតគ្រឿងញៀន ស្លាកសញ្ញា 999 ចំនួន ៩ និងឧបករណ៍សម្រាប់ផលិតផ្សេងទៀត) ។
  - គោលដៅទី៤ : ផ្ទះលេខ ៣៦២AE ផ្លូវលំ ភូមិមានជ័យ ស.ក ស្ទឹងមានជ័យ ខណ្ឌមានជ័យ ។
  - គោលដៅទី៥ : ជាដីចំការនៅខេត្តតាកែវ ដែលបានរកឃើញគ្រឿងញៀនប្រភេទ អូផ្យូម ១កូនក្រឡតូច ។

### ខ.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសុខាភិបាល ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ និងវត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង ខែមករា ឆ្នាំ២០១៣ មានដូចខាងក្រោម :

- សារធាតុគីមីគិតជា គីឡូក្រាម ចំនួន ២.៥៥៤.៣៥០ Kgs
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ចំនួន ៥១ Kgs , ២ g , ២.៥០០ mg និង ៥០០ mcg ។

## ខ.៣. ការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានានៅក្នុងខែមករានេះ សរុបបានចំនួន ៦០ ករណី = ៦៧ សំណាក (សំណាក**អវិជ្ជមានសារធាតុញៀន** ៣ សំណាក = ៥ % និង សំណាក**វិជ្ជមានសារធាតុញៀន** ៦៤ សំណាក = ៩៥ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ៤២ សំណាក = ៦០ % -មេតំហ្វេតាមីនគ្រាប់ ២០ សំណាក = ៣៣ %

-ហេរ៉ូអ៊ីន ១ សំណាក = ១ % -កូកាអ៊ីន ១ សំណាក = ១ %

(**ការបែងចែកលំអិតនៃការងារកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន មាននៅក្នុងឧបសម្ព័ន្ធ ទី២**)

## គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម

### ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម

- **កិច្ចការក្រៅប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :
  - បានចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន និងសម្របសម្រួលជូនមន្ត្រីតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ត្រីតំណាងក្រសួងសុខាភិបាល និងគ្រូពេទ្យ នៃមណ្ឌលបណ្តោះអាសន្ន ឱកាសខ្ញុំពិភពនៃក្តីសង្ឃឹម មណ្ឌលកងរាជអាវុធហត្ថខេត្តបាត់ដំបង-បន្ទាយមានជ័យ និងជីវិតថ្មីភ្នំពេញ ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសថៃ ពីថ្ងៃទី១៣-២៦/០១/២០១៣ សរុប ចំនួន ១៥ រូប និងទស្សនកិច្ចសិក្សាស្វែងយល់ពីការងារគ្រប់គ្រងមជ្ឈមណ្ឌល ចំនួន ៥ រូប (២១-២៦/០១/២០១៣) នៅប្រទេសថៃ ។

## ឃ. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- **កិច្ចការក្នុងប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :
  - បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោង PATROL ដើម្បីពិភាក្សាពីការរៀបចំផែនការសកម្មភាពអនុវត្តន៍គម្រោង PATROL សម្រាប់ឆ្នាំ២០១៣ ។
  - បានចូលរួមធ្វើបទឧទ្ទេសនាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមការស្នើសុំរបស់អង្គការ FHI360 ដល់មន្ត្រីនគរបាលក្រសួងមហាផ្ទៃ ក្នុងវគ្គបណ្តុះបណ្តាលស្តីពីភាពជាដៃគូសហគមន៍ ដើម្បីសុវត្ថិភាពក្នុងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ការជួញដូរមនុស្សនិងការពារអនីតិជន និងការប្រើបំពានគ្រឿងញៀន ដែលមានសិក្ខាកាមសរុបចំនួន **៥៦** រូប ។

- បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកការគាំទ្រផ្នែកថវិកា សម្ភារ និងជំនួយផ្នែកបច្ចេកទេសក្នុងការពង្រឹងសមត្ថភាពក្នុងការប្រមូល ចងក្រង វិភាគ ផ្សព្វផ្សាយ និងរក្សាទុកទិន្នន័យព័ត៌មានពាក់ព័ន្ធបញ្ហាគ្រឿងញៀននៅកម្ពុជា , ការរៀបចំផែនការលំអិតពីសកម្មភាពការងាររបស់មជ្ឈមណ្ឌល , ការពិនិត្យឡើងវិញពីរចនាសម្ព័ន្ធ និងមន្ត្រីរបស់មជ្ឈមណ្ឌល ។
- បានរៀបចំពិធីប្រគល់សម្ភារជូលដល់បណ្ណាល័យសាលានគរបាលកម្ពុជា សម្រាប់កម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើប៉ាន់គ្រឿងញៀន កាលពីថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣ សម្រាប់សាលាចំនួន ៥ គឺ : សាលាមធ្យមវិជ្ជាជីវៈនៃនគរបាល, សាលាមធ្យមបច្ចេកសេនគរបាល, សាលានគរបាលជាតិភូមិភាគ១ ខេត្តស្ទឹងត្រែង, សាលានគរបាលជាតិភូមិភាគ២ ខេត្តកំពង់ចាម, សាលានគរបាលជាតិភូមិភាគ៦ ខេត្តកំពង់ឆ្នាំង ។
- បានរៀបចំពិធីទទួលសម្ភារគម្រោង PATROL របស់អង្គការ UNODC ចំនួន១១មុខ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែនទីមួយៗ (ការិយាល័យ BLO បាវិត ខេត្តស្វាយរៀង និង ក្អមសំណ ខេត្តកណ្តាល) សរុបជាទឹកប្រាក់ចំនួន ៣២.៤៤៦ ដុល្លារសហរដ្ឋអាមេរិក (១៥/០១/២០១៣) ។
- បានរួមដំណើរជាមួយអង្គការ UNOCD ទៅរៀបចំប្រគល់ និងដំឡើងសម្ភារនៅការិយាល័យទំនាក់ទំនងព្រំដែន BLO) បាវិត ខេត្តស្វាយរៀង និង ក្អមសំណ ខេត្តកណ្តាល កាលពីថ្ងៃទី១៦-១៩/០១/២០១៣ ។
- បានរៀបចំកិច្ចប្រជុំពិភាក្សា លើផែនការសកម្មភាពរបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ដើម្បីដាក់សំណើសុំការផ្តល់ជំនួយពីអង្គការ AusAID ។

ក្រៅពីការងារខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចេញសេចក្តីសម្រេចលេខ ០០១/១៣ សសរ .អ.ជ.ប.គ.ញ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលសមាសភាព តួនាទី និងភារកិច្ចការិយាល័យទំនាក់ទំនងព្រំដែន (Border Liaison Office.(BLO) ។

## ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ខែមករាឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ មានដូចខាងក្រោម :

**ង.១. ការងារក្នុងប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- បានចាត់បញ្ជូនបេក្ខជន ១ រូប សម្រាប់ប្រកួតប្រជែងធ្វើជា Attachment officer នៅលេខាធិការដ្ឋានអាស៊ាន ។
- បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពសម្រាប់អនុវត្តខ្លឹមសារកំណត់ហេតុនៃកិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រី កម្ពុជា-វៀតណាម ថ្ងៃទី៣១/០១/២០១៣ ។

**ដោយឡែក :**

✓ **អគ្គរដ្ឋអាជ្ញា នៃសាធារណរដ្ឋកូរ៉េ** បានចាត់តាំងមន្ត្រីសម្របសម្រួល ១ រូប របស់មជ្ឈមណ្ឌលព័ត៌មាននិងសម្រប

សម្រួលប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក សម្រាប់ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មគ្រឿងញៀន (APICC) មកបើកការិយាល័យប្រចាំការ និងធ្វើការងារជាមួយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នជាសមាជិក APICC ។

- ✓ **ខេត្តកំពង់ចាម** តាមការប្តូរវេនគ្នាធ្វើជាម្ចាស់ផ្ទះ បានរៀបចំកិច្ចប្រជុំទ្វេភាគីរវាងស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ជាមួយស្នងការនគរបាលខេត្តបិញហ្វឿក ប្រទេសវៀតណាម កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដើម្បីផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យគ្រឿងញៀន និងការងារលើកកម្ពស់ការយល់ដឹងពីគ្រឿងញៀនដល់ប្រជាពលរដ្ឋនៅតាមភូមិ ឃុំ សង្កាត់ ស្រុក ទាំងសងខាង ។

**ជាមួយនេះដែរ** ក្រសួងមហាផ្ទៃ :

- ✓ កាលពីថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣ នៅរដ្ឋធានីវៀងចន្ទ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចុះហត្ថលេខាជាមួយឯកឧត្តម ត្រឹង ដាយក្វាង រដ្ឋមន្ត្រីក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម លើផែនការសហប្រតិបត្តិការ ឆ្នាំ២០១៣ ដែលនៅក្នុងចំណុច II. ស្តីពីកិច្ចសហប្រតិបត្តិការបង្ការបង្ក្រាបឧក្រិដ្ឋកម្ម រក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម (ចាប់ពីចំណុចទី១ ដល់ ទី៣) គឺមានពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ✓ កាលពីថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣ នៅរដ្ឋធានីវៀងចន្ទ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចុះហត្ថលេខាជាមួយឯកឧត្តម បណ្ឌិត ថងបាន់ សែងអាផន រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ លើកំណត់ហេតុ ឆ្នាំ២០១៣ ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលនៅក្នុងចំណុច (៦.២.) ស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងការត្រួតពិនិត្យនិងគ្រប់គ្រងគ្រឿងញៀនតាមព្រំដែន (ចាប់ពីចំណុច៦.២.១. រហូតដល់ ៦.២.៤.) គឺមានពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## *ការងារផ្សេងៗ :*

### *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ :*

- បន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ ដំណើរការរៀបចំបញ្ចូលផ្ទៀងផ្ទាត់ និងវិភាគទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន ក្នុងការសិក្សា ការអង្កេតរកអត្រា ប្រេវ៉ាឡង់មេរោគអេដស៍ និង ឥរិយាបថប្រព្រឹត្តប្រឈមគ្រោះថ្នាក់ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា[1] ។

---

1 បន្ទាប់ពីបានបញ្ចប់ការប្រមូលទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន សម្រាប់ការសិក្សា ការអង្កេតរកអត្រាប្រេវ៉ាឡង់ មេរោគអេដស៍/ជំងឺអេដស៍ ឥរិយាបថប្រព្រឹត្តប្រឈមគ្រោះថ្នាក់និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿង ញៀននៅកម្ពុជា ។

- បានបញ្ចប់សេចក្តីព្រាងផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣-២០១៥ ។
- បានបន្តពិនិត្យ ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (២១/១២/២០១២) ។

## III. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀនខែមករា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តន៍ទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភា អ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន និងស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អំពីអត្តសញ្ញាណ និងឥទ្ធិពលនៃគ្រឿងញៀន ថ្ងៃទី២៧/០២/២០១៣។

១.២. បន្តរៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវាត់ពានរង្វាន់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្ថានីយទូរទស្សន៍បាយ័ន ដើម្បីបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៣. ត្រៀមទៅចូលរួមកិច្ចប្រជុំជាមួយក្រុមដៃគូអនុវត្តកម្មវិធីអប់រំបង្ការការប្រើបំពានគ្រឿងស្រវឹង និងជំងឺអេដស៍ នៅក្រុងឈាងម៉ៃ ប្រទេសថៃ (០៥-០៧/០២/២០១៣) ដែលរៀបចំដោយអង្គការ IOGT-NTO MOVEMENT ។

១.៤. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៥. បន្តកិច្ចសហការជាមួយកម្មវិធីពេញនិយមតាមបណ្តាស្ថានីយ វិទ្យុ ទូរទស្សន៍ កម្មវិធីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបចំណេះដឹងពីបញ្ហាគ្រឿងញៀន ។

១.៦. ត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពីថ្ងៃទី១៨-២២/០២/២០១៣ ចំនួន ៤៥ រូប ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. បន្តកិច្ចសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការស្រាវជ្រាវជនល្មើសជនជាតិថៃ ៣ នាក់ ពាក់ព័ន្ធនឹងគ្រឿងញៀន តាមការស្នើសុំរបស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

២.២. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតលើសេចក្តីព្រាងស្តីពី យន្តការនិងប្រព័ន្ធចែករំលែកព័ត៌មានពាក់ព័ន្ធនឹងការត្រួតពិនិត្យសារធាតុគីមី ។

### ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. សហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន

ដោយផ្អែកលើសហគមន៍ និងជំរុញដំណើរការរៀបចំបង្កើតនិងពង្រីកបន្ថែមសេវាព្យាបាល អ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ក្នុងប្រព័ន្ធសុខាភិបាលឱ្យបានឆាប់រហ័ស ។

៣.២. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៣. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី ម្តុល/ស៊ីរ៉ាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៤. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀនដែលកំពុងសម្រាកព្យាបាល នៅ តាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៥. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្ត-ភាព ខ្មែរ-សូវៀត ។

៣.៦. រៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. ត្រៀមកិច្ចសហការសម្របសម្រួលជាមួយ ក្រសួងការពារជាតិដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងកម្លាំងឈរ ជើងនៅតាមតំបន់ព្រំដែន នៃកងយោធពលខេមរភូមិន្ទ ។

៤.២. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ស្តីពីការពង្រឹងសមត្ថភាព មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ (កម្មវិធីCBT) ។

៤.៣. បន្តសហការជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា រៀបចំឯកសារបណ្តុះបណ្តាលមន្ត្រីនគរបាលនៅតាមភូមិភាគ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

៤.៤. បន្តកិច្ចសហការជាមួយអង្គការជាដៃគូពាក់ព័ន្ធ លើការងារពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមទៅចូលរួមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៧ នៅខេត្តប្រាឈូបខិរីខាន ប្រទេសថៃ (២០-២៣/០២/ ២០១៣) ។

៥.២. ត្រៀមទៅចូលរួមសន្និសីទស្តីពីកិច្ចប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន អាស៊ី-ប៉ាស៊ីហ្វិក លើកទី១៨ (ADEC 18th) នៅទីក្រុងតូក្យូ ប្រទេសជប៉ុន (ថ្ងៃ២៥-២៧/០២/២០១៣) ។

៥.៣. បន្តកិច្ចសហការជាមួយអ្នកសម្របសម្រួលគម្រោង PATROL របស់អង្គការ UNODC ដើម្បីរៀបចំកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែន កម្ពុជា-ថៃ ។

៥.៤. បន្តកិច្ចសហការជាមួយអ្នកសម្របសម្រួលគម្រោង របស់អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ដើម្បីពង្រឹងសមត្ថ-ភាព ការិយាល័យទំនាក់ទំនងព្រំដែន នៅតាមដងទន្លេមេគង្គ ។

៥.៥. បន្តទំនាក់ទំនងជាមួយស្ថានទូតចិន ពាក់ព័ន្ធនឹងសំណើររបស់ អ.ជ.ប.គ.ញ ស្នើសុំឱ្យជួយរៀបចំទទួលដំណើរទស្សន

កិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់របស់អ.ជ.ប.គ.ញ ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ។

៥.៦. បន្តទំនាក់ទំនងជាមួយស្ថានទូតសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ពាក់ព័ន្ធនឹងសំណើរសុំរបស់ អ.ជ.ប.គ.ញ ឱ្យជួយរៀបចំការផ្លាស់ប្តូរដំណើរទស្សនកិច្ច នៃស្ថាប័នត្រួតពិនិត្យគ្រឿងញៀននៃប្រទេសទាំងពីរ ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិ មានដូចជា :

- បន្តរៀបចំសិក្ខាសាលាជាតិ ដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- បន្តសហការជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ ដំណើរការរៀបចំបញ្ចូល ផ្ទៀងផ្ទាត់ និងវិភាគទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន ក្នុងការសិក្សា ការអង្កេតរកអត្រា ប្រេវ៉ាឡង់មេរោគអេដស៍ និងឥរិយាបថប្រព្រឹត្តប្រឈមគ្រោះថ្នាក់ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា ។
- ត្រៀមសហការជាមួយ អង្គការសុខភាពគ្រួសារអន្តរជាតិ (អេហ្វ.អេច.អាយ) FHI360 រៀបចំកិច្ចពិភាក្សាតុមូលលើការងារកាត់បន្ថយគ្រោះថ្នាក់ និងការងារភូមិ-ឃុំមានសុវត្ថិភាព ។
- បន្តការរៀបចំលិខិតបទដ្ឋាននានា ក្រោមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- ជំរុញការរៀបចំផែនការសកម្មភាពរបស់នាយកដ្ឋាននីមួយៗ សម្រាប់ឆ្នាំ២០១៣ ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក យូ_ស៊ុនឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ឯកឧត្តម កៅ ខុនផារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អ.ជ.ប.គ.ញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ